**រាជបណ្ឌិត្យសភាកម្ពុជា**
**វិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈ**

*អត្ថបទស្រាវជ្រាវ ស្ដីពី*

# ការសិក្សាអង្កេតបឋមអំពីម៉ូដសក់ផ្នួងមួយ នៃចម្លាក់អប្សរនៅប្រាសាទអង្គរវត្ត



*ដោយ* នូ ចាន់សុទី, ម៉ិល វ៉ាសនា, ប្រែង ពិសិដ្ឋ

ខែមករា ឆ្នាំ២០២០

# ការសិក្សាអង្កេតបឋមអំពីម៉ូដសក់ផ្នួងមួយ
# នៃចម្លាក់អប្សរនៅប្រាសាទអង្គរវត្ត

## សេចក្តីផ្តើម

*អង្គរវត្តជាប្រាសាទសាសនាដ៏ធំបំផុតនៅក្នុងពិភពលោក ដែលមានចម្លាក់អប្សរ(អប្សរា) រាប់ពាន់ក្នុងលក្ខណៈដោយឡែកៗគ្នា។ អប្សរទាំងនោះមានរូបរាងតូចច្រឡឹង ដងខ្លួនស្រឡូនសុដន់មូលក្លំ ទឹកមុខញញឹមស្រស់ស្រទន់ និងមានគ្រឿងលំអតាក់តែងកាយយ៉ាងសម្បូរបែប ៖ ការតាក់តែងលំអដោយមកុដច្រើនប្រភេទនៅលើកេសា ការរចនាម៉ូដសក់ប្លែកៗគ្នាជាច្រើនទម្រង់ និង មានគ្រឿងលំអជាស្មៀតផ្កាឬក្បាច់រចនាច្រើនរបៀប ដែលបង្ហាញពីភាពស៊ីវិល័យរបស់ស្ត្រីនៅជំនាន់នោះ។*

*តាមកំណត់ហេតុរបស់ ជីវតាក្វាន់ ដែលបានមកដល់ទឹកដីខ្មែរនៅចុងសតវត្សទី១៣ បានលើកឡើងថា ស្ត្រីខ្មែរនៅជំនាន់នោះនិយមចូលចិត្តបួងសក់។ ហេតុនេះយើងអាចនិយាយបានថា ដើម្បីបួងសក់ចាប់ជាម៉ូដផ្សេងៗបាន លុះណាតែត្រូវទុកសក់វែង ព្រោះថាសក់ខ្លីមិនអាចឱ្យគេធ្វើម៉ូដសក់បត់បែនបានច្រើនទម្រង់នោះទេ។ ការនិយមតាក់តែងម៉ូដសក់គឺអាស្រ័យទៅតាមចំណង់ចំណូលចិត្តរបស់ស្ត្រី ទៅតាមទម្រង់មុខរបស់ស្ត្រី ហើយក៏អាចទៅតាមឋានៈសង្គមផងដែរ។*

*អត្ថបទនេះនឹងបង្ហាញអំពីការសិក្សាអង្កេតជាបឋមលើម៉ូដសក់អប្សរ (ចម្លាក់អប្សរពេញជំហរធំៗ តែរូបភាពយើងលើកយកតែផ្នែកខាងលើ (ក្បាល)មកបង្ហាញ) ដើម្បីបង្ហាញពីលក្ខណៈដោយឡែកគ្នានៃម៉ូដសក់ដែលបានរចនានៅតាមជញ្ជាំង សរសរ ថែវ ឬប្រាង្គប្រាសាទអង្គរវត្ត។ ទោះជាយ៉ាងណា ការសិក្សានេះគ្រាន់តែបង្ហាញអំពីទម្រង់ដោយឡែកខ្លះៗនៃចម្លាក់អប្សរមួយចំនួនដែលយើងបានសិក្សាអង្កេតជាបឋមប៉ុណ្ណោះ។*

## ចំណាត់ថ្នាក់នៃម៉ូដសក់អប្សរ

*តាមការសិក្សាសង្កេតជាបឋមអំពីលក្ខណៈម៉ូដសក់អប្សរនៅប្រាសាទអង្គរវត្ត យើងអាចបែងចែកម៉ូដសក់នៃចម្លាក់អប្សរជាគោលធំៗចំនួនបួនម៉ូដ៖ **ម៉ូដសក់ផ្នួងមួយ ម៉ូដសក់ផ្នួងពីរ**(ខ្លះហៅផ្នួងត្រចៀកទន្សាយ) **ម៉ូដសក់ទម្លាក់ និង ម៉ូដសក់ពាក់គ្រឿងគ្របសក់** (សំណាញ់ឬស្បៃ?ឬក៏ក្បាំង)។ ចំពោះទម្រង់ម៉ូដសក់ទាំងបួននេះ យើងសង្កេតឃើញម៉ូដសក់ផ្នួងមួយមានចំនួនច្រើន*

*ជាងគេ បន្ទាប់មកជាម៉ូដសក់ផ្នូងពីរ ម៉ូដសក់ទម្លាក់ និង មានចំនួនតិចជាងគេគឺម៉ូដសក់ពាក់សំណាញ់ឬគ្រឿងគ្របក្បាលជិតសក់។*

*ខាងក្រោមនេះជាការពិពណ៌នាត្រួសៗអំពីម៉ូដសក់ផ្នូងមួយ ដែលក្នុងនោះមានសណ្ឋានដោយឡែកៗគ្នាជាច្រើនទៀត។*

## ម៉ូដសក់ផ្នូងមួយ

*ម៉ូដសក់ផ្នូងមួយមានច្រើនសណ្ឋានផ្សេងៗគ្នា ៖ សណ្ឋានបួងច្បូតឡើងលើ សណ្ឋានបួងច្បូតទម្លាក់ខាងឆ្វេងឬខាងស្តាំ សណ្ឋានបួងបត់សក់ចូលផ្នូងដោយរចនាសក់ទម្លាក់មកខាងឆ្វេងឬខាងស្តាំឬច្បូតត្រង់ឡើងលើ សណ្ឋានសក់កាត់ខ្លីខាងមុខនិងសិតគាស់បញ្ឈរឡើង សណ្ឋានសក់កាត់ខ្លីខាងមុខហើយចាប់ជាកង់ៗ ឬ ជាក្បែបៗ ឬធ្វើផ្នត់សក់បាំងគ្របត្រចៀកឬបញ្ចេញទងត្រចៀកក៏មាន ។ល។*

### *ម៉ូដសក់ផ្នូងមួយច្បូតឡើងលើត្រង់*



*រូបទី១*



*រូបទី២*

*ម៉ូដសក់ចម្លាក់អប្សរទាំងពីរខាងលើនេះស្ថិតក្នុងម៉ូដសក់ផ្នូងមួយច្បូតឡើងលើត្រង់ដូចគ្នា (ទោះបី ម៉ូដសក់រូបទី២ កោងកាច់តិចតួចក្តី) ប៉ុន្តែមានរបៀបបួងក្ងួចខុសគ្នា ដែលនេះជារបៀប(ម៉ូដ)ផ្សេងគ្នា។ ចំពោះគ្រឿងលំអសក់របស់អប្សរទាំងពីរនេះក៏មានលក្ខណៈខុសគ្នាដែរ ដោយរូបទី១ មានគ្រឿងតាក់តែងលំអសក់ជាស្នៀតរបៀបជាផ្កាចំប៉ា(តែមួយប្រភេទ)ចំនួនប្រាំបី ហើយភាគច្រើនស្នៀតផ្កាទាំងនោះសៀតពីក្រោយផ្នូងលើកលែងផ្កាចំនួនពីរសៀតនៅផ្នែកខាងក្រោម*

ចំហៀងសងខាងត្រចៀក។ ស្នៀតរបៀបផ្កាទាំងនោះសៀតពត់ទម្លាក់រៀងគ្នាមកខាងឆ្វេងនិងខាងស្តាំ ដោយម្ខាងៗមានស្នៀតចំនួនបួន។ នៅតាមគល់ផ្នួងសក់មានរចនាជាខ្សែរំយោលសន្ទឹកខ្ទីៗព័ទ្ធជុំវិញ ចំណែកនៅខាងមុខមានការរចនាស្រដៀងនឹងបូសក់សម្រាប់បិទបាំងលំអជើងសក់។ ចំណែករូបទី២ មានគ្រឿងលំអតាក់តែងសក់ជាស្នៀតរបៀបផ្កាពីរប្រភេទផ្សេងគ្នាចំនួនប្រាំបីស្នៀត(ផ្ការំដួលចំនួន២ និងផ្កាចំប៉ាចំនួន៦) ។ ស្នៀតទាំងអស់សៀតនៅពីខាងក្រោយផ្នួងរូចពត់ទម្លាក់រៀងគ្នាមកខាងឆ្វេងនិងខាងស្តាំ ដោយម្ខាងៗមានស្នៀតចំនួនបួនដូចគ្នា តែស្នៀតផ្ការំដួលសៀតនៅខាងលើគេ។ ក្រៅពីនេះ អប្សរនេះមានលំអដោយក្បួងផ្កានិងខ្សែរំយោលព័ទ្ធជុំវិញគល់ផ្នួងសក់។ នៅផ្នែកខាងមុខមានខ្សែរំយោលតែមួយជាន់ ដែលបង្ហាញឱ្យឃើញនូវសរសៃសក់ពាក់កណ្តាល តែផ្នែកចំហៀងសងខាងប្រហែលរុំព័ទ្ធទៅក្រោយគឺមានរំយោលពីរជាន់គ្របលើសក់។

**ម៉ូដសក់ផ្នួងមួយច្បូតឡើងលើរាងអន្ទង់អាំង**



រូបទី៣



រូបទី៤

ម៉ូដសក់ចម្លាក់អប្សរទាំងពីរខាងលើនេះស្ថិតនៅក្នុងម៉ូដសក់ផ្នួងមួយច្បូតឡើងលើរាងអន្ទង់អាំងដូចគ្នា ប៉ុន្តែការច្បូតសក់ឡើងលើមិនមានលក្ខណៈដូចគ្នាទេ ដោយរូបទី៣ ការច្បូតសក់ឡើងលើមានពត់ពេនច្រើនជាងរូបទី៤ ។ ជាមួយគ្នានេះ របៀបបួងក្បួចសក់ក៏មិនមានលក្ខណៈដូចគ្នាដែរ។

ចំពោះគ្រឿងលំអសក់របស់អប្សរទាំងពីរមានការតាក់តែងដោយស្នៀតរបៀបជាផ្កាដូចគ្នា ប៉ុន្តែប្រភេទផ្កា លក្ខណៈនៃផ្កា និងក្បាច់ចម្លាក់នៃផ្កានោះមិនដូចគ្នាទេ ដោយរូបទី៣ តាក់តែង

លំអដោយស្នៀតរបៀបជាផ្កាមានទ្រនុងឬស្រទាប់របៀបជាផ្កាចំប៉ា សៀតនៅសងខាងគល់ផ្នួង ដោយម្ខាងៗមានសៀតស្នៀតចំនួនពីរ។ ចម្លាក់អប្សរនេះមានការសឹកខូចខាតនូវទម្រង់លក្ខណៈខ្លះៗ ដែលធ្វើឱ្យយើងមិនអាចមើលដឹងថាជាការរចនាសក់ឆ្នួតៗជាលក្ខណៈសរសៃសក់ឬជាទម្រង់ផ្កាច្បាស់លាស់នោះទេ ប៉ុន្តែទម្រង់និងរបៀបបួងសក់បែបនេះ មានរូបចម្លាក់ផ្សេងទៀតដែលនៅច្បាស់ អាចឱ្យយើងកំណត់អំពីអត្តសញ្ញាណចម្លាក់អប្សរនេះបានថាជាសរសៃ សក់។ ដោយឡែក នៅរូបទី៤ មានការតាក់តែងលំអដោយស្នៀតរបៀបជាផ្កាស្វាឬផ្កាដូងសរុបចំនួន ១២(ដប់ពីរ)ស្នៀត សៀតពីក្រោយផ្នួងសក់រៀងគ្នានៅខាងឆ្វេងនិងខាងស្តាំនៃសក់ច្បូត ដោយម្ខាងៗមានស្នៀតចំនួនប្រាំមួយ ក្នុងនោះមានស្នៀតចំនួនបួនសៀតពីលើ និង ស្នៀតចំនួនពីរសៀតពត់ទម្លាក់ចុះ។ ក្រៅពីការតាក់តែងលំអដោយស្នៀត រូបទី៤ មានការតាក់តែងលំអដោយពាក់ក្បាំងមកុដថែមទៀត ដែលក្បាំងមកុដនេះមានចង្វាយក្បាច់ចំនួនពីរខ្សែគឺចង្វាយក្បាច់ពងត្រីនិងចង្វាយក្បាច់ត្របកឈូក។ ការណ៏ដែលយើងហ៊ានហៅថាជាក្បាំងមកុដ គឺដោយសារទម្រង់លក្ខណៈនៃក្បាំងបែបនេះមានលក្ខណៈដូចគ្នាទៅនឹងទម្រង់ក្បាំងមកុដអប្សរមួយចំនួនទៀត។

**ម៉ូដសក់ផ្នួងមួយច្បូតឡើងលើទម្លាក់ឆ្វេង**



រូបទី៥



រូបទី៦

ម៉ូដសក់ចម្លាក់អប្សរទាំងពីរខាងលើនេះស្ថិតក្នុងម៉ូដសក់ផ្នួងមួយច្បូតឡើងទម្លាក់ខាងឆ្វេងដូចគ្នា ប៉ុន្តែរបៀបនៃការបួងក្តួចមិនមានលក្ខណៈដូចគ្នាទេ។ ដោយឡែក គ្រឿងលំអសក់និងការតាក់តែងរបស់អប្សរទាំងពីរនេះក៏មានរបៀបខុសគ្នាដែរ ដោយម៉ូដសក់រូបទី៥ មានលំអដោយ

*គួងផ្កាពីរជាន់ព័ទ្ធជុំវិញគល់ផ្នួង ហើយមានការតាក់តែងលំអដោយស្នៀតចំនួនបួន សៀតពីក្រោយផ្នួងសក់រៀងគ្នានៅខាងឆ្វេងនិងខាងស្តាំនៃសក់ច្បូត ដោយម្ខាងៗមានស្នៀតចំនួនពីរ (ស្នៀតមួយសៀតចុងឡើងលើនិងមួយទៀតសៀតពត់ចុងទម្លាក់ចុះ)។ ចំណែកម៉ូដសក់ចម្លាក់អប្សររូបទី៦ មានគ្រឿងតាក់តែងដោយខ្សែរំយោលសន្ទឹកខ្ចីៗព័ទ្ធជុំវិញគល់ផ្នួងសក់ និងមានលំអដោយក្បាំងមកុដបាំងបិទជើងសក់។ ក្បាំងមកុដនេះផ្សំឡើងដោយចង្វាយក្បាច់ចំនួនពីរខ្សែគឺចង្វាយក្បាច់ពងត្រីនិងចង្វាយក្បាច់ត្របកឈូក។*

**ម៉ូដសក់ផ្នួងមួយច្បូតឡើងលើ មានសក់ក្បាំងមុខ**



*រូបទី៧*

*ម៉ូដសក់ចម្លាក់អប្សរខាងលើនេះស្ថិតក្នុងម៉ូដសក់ផ្នួងមួយច្បូតឡើងលើ ហើយមានសក់ក្បាំងមុខ។ សក់ក្បាំងមុខនៃអប្សរនេះបានកាត់ជាពីរស្រទាប់ សិតបញ្ឈរពត់កោងអបជាប់ផ្ទៃមុខបាំងគ្របស្លឹកត្រចៀក និងមានលំអដោយបូសក់គ្របជើងសក់ខាងមុខ។ ចំពោះគ្រឿងតាក់តែងលំអសក់របស់អប្សរនេះ មានសៀតស្នៀតរបៀបជាផ្កាចំប៉ានិងផ្កាដូងសរុបចំនួន១៥(ដប់ប្រាំ)។ ស្នៀតទាំងអស់សៀតនៅពីខាងក្រោយផ្នួងសក់នៅខាងឆ្វេងឬខាងស្តាំនៃសក់ច្បូត ក្នុងនោះស្នៀតរបៀបផ្កាដូងត្រូវសៀតទម្លាក់ចុះក្រោម។*

## ម៉ូដសក់ផ្នួងមួយច្បូតឡើងលើទម្លាក់ស្ដាំ មានក្រង



*រូបទី៨*

ម៉ូដសក់ចម្លាក់អប្សរខាងលើនេះស្ថិតក្នុងម៉ូដសក់ផ្នួងមួយច្បូតឡើងលើ ទម្លាក់ខាងស្ដាំ ដោយគេក្រងសក់ជុំវិញក្បាលដល់ត្រឹមចំណុចបួងក្បួច ហើយចាប់ច្បូតសក់ទម្លាក់មកខាងស្ដាំ ត្រង់ពាក់កណ្ដាលសក់ ហើយពត់ចុងសក់រាងឡើងបន្តិចៗ អប្សរនេះមានគ្រឿងតាក់តែងលំអសក់ដោយស្នៀតរបៀបជាផ្កាវិដ្ឋូលចំនួនពីរ និងផ្កាស្វាប្នផ្កាដូងចំនួនបួន សៀតពីក្រោយផ្នួងសក់រៀងគ្នានៅខាងឆ្វេងនិងខាងស្ដាំនៃសក់ច្បូត ដោយម្ខាងៗមានស្នៀតរបៀបជាផ្កាវិដ្ឋូលចំនួនមួយ សៀតអបនឹងសក់ច្បូតឡើង និងស្នៀតរបៀបជាផ្កាស្វាប្នផ្កាដូងចំនួនពីរ សៀតពត់ទម្លាក់ចុះក្រោមជារំយោល។

**ម៉ូដសក់ផ្នួងមួយច្បូតឡើងលើទម្លាក់ស្គាំ មានសក់ក្បាំងមុខ**



*រូបទី៩*

ម៉ូដសក់ចម្លាក់អប្សរខាងលើនេះស្ថិតក្នុងម៉ូដសក់ផ្នួងមួយច្បូតឡើងលើទម្លាក់ស្គាំ និងមានសក់ក្បាំងមុខ។ នៅផ្នែកខាងមុខមានលំអដោយក្បាំង(បូ?)គ្របជើងសក់ និងមានស្នៀតរបៀបជាផ្កាចំនួនបី ដោយមានស្នៀតពីរពត់កោងទម្លាក់ចុះ និងស្នៀតមួយទៀតសៀតឱ្យចុងឡើងលើប្រៀបដូចពន្លកផ្កាដុះឡើង។

**ម៉ូដសក់ផ្នួងមួយច្បូតបត់ចូលផ្នួងនិងច្បូតពត់ចុងសក់ឡើងលើត្រង់ ហើយរចនាដូចពាក់មួក**



*រូបទី១០*

ម៉ូដសក់ចម្លាក់អប្សរខាងលើនេះស្ថិតក្នុងម៉ូដសក់ផ្នួងមួយច្បូតបត់ចូលផ្នួងនិងពត់ចុងសក់ត្រង់ឡើង  ជាមួយនឹងការរចនាសិតគាស់សក់បញ្ឈរឡើងដូចពាក់មួក។  អប្សរនេះមានគ្រឿងតាក់តែងលំអសក់ដោយស្មៀតរបៀបជាផ្កាចំប៉ាចំនួនពីរ  ស្មៀតនៅចំហៀងសងខាងផ្នួងសក់ហើយពត់រាងកោងទម្លាក់ចុះ។

**ម៉ូដសក់ផ្នួងមួយច្បូតឡើងលើទម្លាក់ឆ្វេង មានសក់ក្បាំងមុខ**



រូបទី១១

ម៉ូដសក់ចម្លាក់អប្សរទាំងនេះស្ថិតក្នុងម៉ូដសក់ផ្នួងមួយច្បូតឡើងលើទម្លាក់ឆ្វេង  និងមានសក់ក្បាំងមុខ។ សក់ក្បាំងមុខនៃអប្សរទាំងនេះបានសិតគាស់បញ្ឈរ ពុះញែកឆ្វេងស្តាំ ពត់កោងអបជាប់ផ្ទៃមុខដល់ត្រចៀកម្ខាងៗ។ អប្សរនេះមានគ្រឿងតាក់តែងលំអសក់ដោយស្មៀតរបៀបជាផ្កាចំប៉ានិងស្មៀតផ្សេងៗទៀតមានទម្រង់ដោយឡែកគ្នា។

**ម៉ូដសក់ផ្នួងមួយច្បូតបត់ចូលផ្នួងទម្លាក់សងខាង មានសក់ក្បាំងមុខ**



រូបទី១២

ម៉ូដសក់អប្សរនេះស្ថិតក្នុងម៉ូដសក់ផ្នួងមួយច្បូតបត់ចូលផ្នួងទម្លាក់ចុងសក់មកសងខាង និងមានសក់ក្បាំងមុខទៀត។ សក់ក្បាំងមុខនេះប្រហែលធ្វើឡើងដោយការកាត់សក់ខាងមុខឱ្យខ្លី សិតគាស់បញ្ឈរឡើង ហើយនៅផ្នែកខាងៗសិតគាស់រាងញែកចេញពីគ្នាបន្តិច។ អប្សរនេះមាន គ្រឿងតាក់តែងលំអសក់ដោយស្នៀតរបៀបជាផ្កាចំប៉ានិងផ្កាឈូកក្រពុំដែលសរុបទាំងអស់មាន ស្នៀតចំនួនប្រាំ។ ស្នៀតទាំងអស់សៀតនៅពីខាងក្រោយផ្នួង ដោយស្នៀតរបៀបជាផ្កាឈូក(ធំ) សៀតពីលើនៅកណ្ដាលផ្នួង និងស្នៀតរបៀបជាផ្កាចំប៉ាសៀតម្ខាងៗចំនួនពីរ។

### ម៉ូដសក់ផ្នួងមួយច្បូតបត់ចូលផ្នួង មានសក់ក្បាំងមុខ



រូបទី១៣

ម៉ូដសក់ចម្លាក់អប្សរខាងលើនេះស្ថិតក្នុងម៉ូដសក់ផ្នួងមួយច្បូតបត់ចូលផ្នួង និងមានសក់ក្បាំងមុខ។ សក់ច្បូតបត់ចូលផ្នួងមានបញ្ចេញចុងសក់ងឡើងបន្តិច ឯសក់ក្បាំងមុខប្រហែលធ្វើឡើងដោយការកាត់សក់ខាងមុខឱ្យខ្លី សិតគាស់បញ្ឈរឡើងពត់កោងអបជាប់ផ្ទៃមុខបាំងគ្របស្មឹកត្រចៀក។ អប្សរនេះមានគ្រឿងតាក់តែងលំអសក់ដោយស្នៀតរបៀបជាផ្កាចំប៉ាចំនួនពីរ សៀតនៅគល់ផ្នួងពត់ទម្លាក់(ស្នៀតមួយសៀតខាងស្ដាំនិងស្នៀតមួយទៀតសៀតខាងឆ្វេងនៃសក់ច្បូតបត់ចូលផ្នួង)។

## ម៉ូដសក់ផ្នួងមួយចម្បូតបត់ចូលផ្នួងទម្លាក់ស្តាំ មានសក់ក្បាំងមុខ



រូបទី១៤

ម៉ូដសក់ចម្លាក់អប្សរខាងលើនេះស្ថិតក្នុងម៉ូដសក់ផ្នួងមួយចម្បូតបត់សក់ចូលផ្នួង រួចទម្លាក់ចុងសក់មកខាងស្តាំ និងមានសក់ក្បាំងមុខ។ សក់ក្បាំងមុខនេះប្រហែលធ្វើឡើងដោយការកាត់សក់ខាងមុខឱ្យខ្លី សិតគាស់បញ្ឈរឡើងពុះញែកឆ្វេងស្តាំ ហើយពត់កោងអបជាប់ផ្ទៃមុខបាំងគ្របស្លឹកត្រចៀក។

អប្សរនេះមានគ្រឿងតាក់តែងលំអសក់ដោយស្នៀតរបៀបជាផ្កាចំនួនបី ៖ ស្នៀតទម្រង់រុក្ខជាតិផ្កាជាមែកចំនួនមួយនិងស្នៀតទម្រង់ផ្កាចំប៉ាចំនួនពីរ។ ស្នៀតទម្រង់រុក្ខជាតិផ្កាជាមែកសៀតនៅកណ្តាល ឯស្នៀតទម្រង់ផ្កាចំប៉ាសៀតមួយម្ខាងអមសងខាង។

## ម៉ូដសក់ផ្នួងមួយច្បួតបត់ចូលផ្នួងទម្លាក់ឆ្វេង



រូបទី១៥

ម៉ូដសក់ចម្លាក់អប្សរខាងលើនេះស្ថិតក្នុងម៉ូដសក់ផ្នួងមួយច្បួតបត់ចូលផ្នួង រូបទម្លាក់ចុងសក់មកខាងឆ្វេង។ ម៉ូដសក់នេះមានលំអដោយក្បួងនិងខ្សែរំយោលសន្ទឹកខ្ទីៗព័ទ្ធជុំវិញផ្នួងសក់ និង មានសៀតស្មៀតរបៀបជាផ្កាចំប៉ាចំនួនប្រាំពីរ ដោយក្នុងចំណោមស្មៀតទាំងប្រាំពីរនេះមានស្មៀតមួយសៀតពត់ទម្លាក់ចុះខាងស្តាំ។ ក្រៅពីនេះមានស្មៀតរុក្ខជាតិផ្កាជាមែកមួយទងសៀតពីលើនៅចំហៀងគល់ផ្នួងខាងស្តាំ។

## ម៉ូដសក់ផ្នួងមួយច្បួតបត់ចូលផ្នួងនិងច្បួតពត់ចុងសក់ឡើងលើត្រង់ មានសក់ក្បាំងមុខ



រូបទី១៦

ម៉ូដសក់ចម្ងាក់អប្សរខាងលើនេះស្ថិតក្នុងម៉ូដសក់ផ្នួងមួយច្បូតបត់ចូលផ្នួង រួចច្បូតពត់ចុង សក់ឡើងលើត្រង់ ព្រមទាំងមានសក់ក្បាំងមុខ។ សក់ក្បាំងមុខនៃអប្សរនេះបានកាត់ជាពីរស្រទាប់ សិតបញ្ឈរ ហើយពុះញែកពត់កោងអបជាប់ផ្ទៃមុខបាំងគ្របស្លឹកត្រចៀក។ ចំពោះគ្រឿងតាក់តែងលំអសក់របស់អប្សរនេះមានស្នៀតរបៀបជាផ្កាចំប៉ាចំនួនបួន សៀតពីលើនៅខាងក្រោយនៃគល់ផ្នួងសក់ សងខាងនៃសក់បួងច្បូតឡើង ដោយក្នុងនោះស្នៀតមួយនៅខាងក្រោម (ទាំងពីរខាង)ពត់ទម្លាក់ចុះ។

## ម៉ូដសក់ផ្នួងមួយច្បូតបត់ចូលផ្នួង



រូបទី១៧

ម៉ូដសក់ចម្ងាក់អប្សរខាងលើនេះស្ថិតក្នុងម៉ូដសក់ផ្នួងមួយច្បូតបត់ចូលផ្នួង តែមិនឃើញមានការរចនាចេញចុងសក់ទៅខាងណានោះទេ ដោយប្រហែលចុងសក់បត់ទៅខាងក្រោយឬបត់ចូលក្នុងសំណុំគល់ផ្នួងសក់។ ម៉ូដសក់នេះមានលម្អដោយខ្សែរំយោលព័ទ្ធជុំវិញផ្នួង និង មានស្នៀតរបៀបជាផ្កាចំប៉ាចំនួនប្រាំមួយសៀតនៅសងខាងនៃសក់បួងច្បូត ដោយម្ខាងៗមានសៀតស្នៀតផ្កាចំនួនបី (ស្នៀតផ្កាចំនួនពីរឡើងលើនិងស្នៀតផ្កាមួយទៀតពត់ទម្លាក់)។

ម៉ូដសក់ផ្នួងមួយច្បូតបត់ចូលផ្នួងនិងច្បូតពត់ចុងសក់កោងទម្លាក់ចុះ



រូបទី១៨

ម៉ូដសក់ចម្លាក់អប្សរខាងលើនេះស្ថិតក្នុងម៉ូដសក់ផ្នួងមួយច្បូតបត់ចូលផ្នួង ហើយច្បូតពត់ចុងសក់កោងឡើងទម្លាក់ចុះ។ អប្សរនេះមានគ្រឿងតាក់តែងលំអសក់ដោយស្មៀតរបៀបជាផ្កាស្លាឬផ្កាដូងសរុបចំនួនប្រាំបី។ ស្មៀតទាំងនេះសៀតម្ខាងបួននៅសងខាងសក់បួងច្បូតបត់ចូលផ្នួង ដោយស្មៀតពីរឡើងលើនិងស្មៀតពីរទៀតសៀតពត់ទម្លាក់ចុះ។

## សេចក្ដីសន្និដ្ឋាន

តាមការសិក្សាអង្កេតជាបឋមនេះ យើងឃើញម៉ូដសក់ផ្នួងមួយនៃចម្លាក់អប្សរខ្លះមានការរចនាប្រហាក់ប្រហែលគ្នា ប៉ុន្តែមានបន្ថែមគ្រឿងតាក់តែងលំអខុសៗគ្នា។ របៀបនៃការប្រើគ្រឿងតាក់តែងលំអលើសក់ក៏ជារបៀបនៃការលេងម៉ូដសក់ផ្នួងមួយឱ្យមានលក្ខណៈដោយឡែកៗគ្នារបស់អប្សរដែរ ដោយអប្សរខ្លះសៀតផ្កាឬស្មៀតទៅតាមទម្រង់ម៉ូដសក់របស់ខ្លួន។

អត្ថបទជាបន្តបន្ទាប់នាពេលដ៏ខ្លីខាងមុខនេះ យើងនឹងព្យាយាមសិក្សាអង្កេតនិងបង្ហាញជូនអំពីម៉ូដសក់ផ្សេងទៀតនៃចម្លាក់អប្សរនៅប្រាសាទអង្គរវត្ត មានជាអាទិ៍ ម៉ូដសក់ផ្នួងពីរ(ខ្លះហៅផ្នួងត្រចៀកទន្សាយ) ម៉ូដសក់ទម្លាក់ និង ម៉ូដសក់ពាក់គ្រឿងគ្របសក់ ។